# សូមចូលរួមយ៉ាងសកម្ម ក្នុងការការពារកុមារ

**ត្រូវដឹងពីអ្វីដែលកុមារ ធ្វើនៅលើអនឡាញ ដើម្បីរក្សាសុវត្ថិភាពរបស់ពួកគេ**





**ការប្រើប្រាស់អ៊ីនធឺណិតរបស់កុមារ** គឺជាផ្នែកសំខាន់មួយនៃការអភិវឌ្ឍរបស់ពួកគេ ប៉ុន្តែវាក៏អាចបង្កហានិភ័យផងដែរ។ មានជនខិលខូចនៅលើអនឡាញដែលព្យាយាមប្រាស្រ័យទាក់ទងជាមួយកុមារដើម្បីកេងប្រវ័ញ្ចផ្លូវភេទ។

**ការកេងប្រវ័ញ្ចតាមអនឡាញ**

ជួនកាលវាពិបាកកំណត់ពីអំពើកេងប្រវ័ញ្ចតាមអនឡាញព្រោះវាមិនតែងតែពាក់ព័ន្ធនឹងការជួបផ្ទាល់រវាងជនល្មើស និងកុមារនោះទេ។ ឧទាហរណ៍ជនល្មើសព្យាយាមបញ្ចុះបញ្ចូលកុមារឱ្យផ្ញើរូបថត ឬវីដេអូផ្លូវភេទរបស់ពួកគេតាមអនឡាញ។ ប៉ុន្តែបើទោះបីជាមានការជួបផ្ទាល់ ឬមិនផ្ទាល់ វានៅតែជាអំពើខុសច្បាប់ និងបង្កគ្រោះថ្នាក់ដល់កុមារ។

**សូមនិយាយជាមួយកុមារ** អំពីការប្រាស្រ័យទាក់ទងតាមអនឡាញដែលមានសុវត្ថិភាព និងធ្វើឱ្យពួកគេមានទំនុកចិត្ត ក្នុងការចែករំលែកបទពិសោធន៍តាមអនឡាញជាមួយអ្នក។ សូមស្តាប់ដោយយកចិត្តទុកដាក់នូវតម្រូវការរបស់ពួកគេ ហើយប្រសិនបើពួកគេប្រាប់ពីការរំលោភបំពាន សូមបង្ហាញការអាណិតអាសូរ និងផ្តល់ការគាំទ្រ ហើយមិនត្រូវស្តីបន្ទោសពួកគេ និងសូមចូលរួមរាយការណ៍។



ក្នុងករណីមានការសង្ស័យពីអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សូមរាយការណ៍ទៅកាន់ទូរស័ព្ទ៖ **092 311 511** ឬគេហទំព័រ៖ **www.internethotlinecambodia.org**



ផលិតដោយ៖ APLE

ឧបត្ថម្ភការបោះពុម្ពដោយ៖ USAID ជំនួយពីប្រជាជនអាមេរិក unicef for every child